ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី
CHIEF (CAMBODIA) SPECIALIZED BANK PLC.



# ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី
## CHIEF (CAMBODIA) SPECIALIZED BANK PLC.

# របាយការណ៍ប្រចាំឆ្នាំ ANNUAL REPORT ២០១៧
2017

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី
CHIEF (CAMBODIA) SPECIALIZED BANK PLC.

www.chiefbank.com.kh

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានបង្កើតឡើងក្នុងឆ្នាំ២០១៣ គឺជា ធនាគារឯកទេសដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាដែល Chief Financial Group (Cambodia) Limited ជាម្ចាស់ភាគហ៊ុន និងមានមូលដ្ឋាននៅទីក្រុងហុងកុង បង្កើតឡើងនៅក្រោមច្បាប់ British Virgin Islands។ ដោយសារតែ ភាពជោគជ័យនៃប្រតិបត្តិការ ធនាគារ ឈីហ្វ ចេះតែបន្តឥតឈប់ឈរ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានទទួលលិខិត យល់ព្រមជា គោលការណ៍ ពីធនាគារជាតិ នៃកម្ពុជា នៅក្នុងឆ្នាំ២០១៦ ដែលអនុញ្ញាតឱ្យធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី កម្លាយខ្លួនទៅជា ធនាគារពាណិជ្ជ ដោយត្រូវបំពេញ ស្របទៅតាមលក្ខខណ្ឌចាំបាច់នានា មួយចំនួនរបស់ធនាគារជាតិនៃកម្ពុជា។

# តារាងមាតិកា


| | | |
|---|---|---|
| ០១ | សារស្វាគមន៍ពី ប្រធានក្រុមប្រឹក្សាភិបាល | ២ |
| ០២ | សារស្វាគមន៍ពី អគ្គនាយកធនាគារ | ៣-៤ |
| ០៣ | ក្រុមប្រឹក្សាភិបាល | ៥-៦ |
| ០៤ | អគ្គនាយក | ៧ |
| ០៥ | រចនាសម្ព័ន្ធ | ៨-៩ |
| ០៦ | ព័ត៌មានសង្ខេបអំពីធនាគារ | ១០ |
| ០៧ | ផលិតផល និង សេវា | ១១-១២ |
| ០៨ | ព័ត៌មានសង្ខេបអំពី Chief Holdings | ១៣ |
| ០៩ | ព័ត៌មានសង្ខេបអំពី ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | ១៤-១៥ |
| ១០ | វប្បធម៌ការងារ | ១៦ |
| ១១ | ការបំពេញចិត្តអតិថិជន | ១៧ |
| ១២ | ទិសដៅយុទ្ធសាស្រ្ត ឆ្នាំ២០១៧ | ១៨-១៩ |
| ១៣ | ការពង្រីកអាជីវកម្ម | ២០ |
| ១៤ | បណ្តាញសាខា | ២១ |
| ១៥ | របាយការណ៍ក្រុមប្រឹក្សាភិបាល | ២៣-២៥ |
| ១៦ | របាយការណ៍សវនករឯករាជ្យ | ២៦-៦៣ |

# សារស្វាគមន៍ពី ប្រធានក្រុមប្រឹក្សាភិបាល



“(ទីណាមានមនុស្ស ទីនោះមាន ឈីហ្វ, The Chief Way) ទស្សនៈ អាជីវកម្មតែមួយ វាគឺជាមធ្យោបាយមួយ ដើម្បីបង្កើតនូវទំនុកចិត្តអោយគ្នាទៅវិញទៅមក និង ទំនាក់ទំនងជាដៃគូរ ជាមួយអតិថិជនរបស់យើង, ជាមធ្យោបាយទៅរកការរីក ចំរើនប្ដុំប្ដើន និង ជាផ្លូវដែរអាជីវកម្មរបស់យើងត្រូវបានបង្កើត ឡើងដោយភាពស្មោះត្រង់ និង សីលធម៌។”

Mr. CHAU Chung Kai Peter
ស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល

## សារស្វាគមន៍ពី ប្រធានក្រុមប្រឹក្សាភិបាល

ក្រៅពីកំណើនតណទានពួកយើងក៏ទទួលបាននូវអតិថិជន និងបុគ្គលិកដែរមានភាពស្មោះត្រង់យ៉ាងធំធេងផងដែល។ កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជានៅតែជឿនលឿននិងរឹងមាំដ៏ដែលអាចប្រាប់យើងពីការផ្លាស់ប្ដូរយ៉ាងឆាប់រហ័យពីទិដ្ឋភាពរីកចម្រើនអំពី ប្រតិបត្តិការវិស័យធនាគារ និងការធ្វើអោយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រសើរឡើង។

ក្នុងឆ្នាំនេះផងដែរ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានផ្លាស់ទីតាំងការិយាល័យកណ្ដាល ទៅកាន់អាគារ ផ្ទាល់ខ្លួនថ្មី ដែលស្ថិតនៅក្នុងទំតាំងដ៏ប្រសើរសម្រាប់វិស័យធនាគារ។

ជាពិសេសយើងបានធ្វើឱ្យកាន់តែមានភាពប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រង បណ្ដាញទាំងមូលដែលផ្ដល់នូវលក្ខខណ្ឌសុវត្ថិភាពរឹងមាំ និងស្ថិរភាពសម្រាប់ប្រតិបត្តិការ។ នៅពេលដែលយើងធ្វើការពង្រីកអាជីវកម្មរបស់យើងជា សកល ធនាគារ យើងត្រូវបានបញ្ចូលនូវគំរូអាជីវកម្មមួយដែលធ្វើការផ្ដោតលើអតិថិជនជាមួយ បច្ចេកវិទ្យាទំនើប ក្នុងគោលបំណងផ្ដល់នូវដំណោះស្រាយដ៏ទូលំទូលាយ ផ្នែកហិរញ្ញវត្ថុព្រមទាំងដំណើរការប្រតិបត្តិការដែលមានលក្ខណៈប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។បន្ថែមពីនេះទៀត យើងផ្ដល់ឲ្យបុគ្គលិករបស់យើងនូវវិជ្ជាជីវៈគ្រប់គ្រាន់ និងវគ្គបណ្ដុះបណ្ដាលថ្មីៗ ដើម្បីទទួលយកនូវភាពជាអ្នកដឹកនាំគ្រប់ពេលវេលា។ យុត្តិសាស្ត្ររបស់យើងគឺត្រូវបានបង្ហាញដោយភាពជោគជ័យ ការកើនឡើងយ៉ាងឆាប់រហ័សនិងជាប់លាប់សម្រាប់ទស្សវត្សរ៍ចុងក្រោយនេះ។ ក្រុមការងាររបស់យើង ជ្រើសរើសបុគ្គលិកក្នុងស្រុកប្រកបដោយវិជ្ជាជីវៈ និងការជួយជ្រោមជ្រែងពីសំណាក់ ក្រុមហ៊ុនមេ ដែលមាន ទីតាំងក្នុងទីក្រុងហុងកុង។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី គឺជាផ្នែកមួយនៃមូលដ្ឋានទំនាក់ទំនងវប្បធម៌ នៅក្នុងគោលការណ៍ សុចរិតភាព ប្រុងប្រយ័ត្ន និងតម្លាភាព។ ក្រុមការងាររបស់យើង ជ្រើសរើសនូវបុគ្គលិកក្នុងស្រុកប្រកបដោយវិជ្ជាជីវៈ និងការជួយជ្រោមជ្រែងពីសំណាក់ក្រុមហ៊ុនមេដែលមាន ទីតាំងក្នុងទីក្រុងហុងកុង។ ធនាគារឯកទេស ឈីហ្វ (ខេមប៉ូឌា) ភីអិលស៊ី គឺជាផ្នែកមូលដ្ឋានវប្បធម៌ទំនាក់ទំនងមួយនៅក្នុងគោលការណ៍ សុចរិតភាពប្រុងប្រយ័ត្ន និងតម្លាភាព។

លោកអ្នកអាចអញ្ជើញចូលទៅកាន់គេហទំព័រ ឬវេបសាយរបស់ធនាគារយើង ក៏ដូចជាសាខានានា ដើម្បីទទួលបាននូវព័ត៌មាននៃសេវាកម្មដ៏ល្អផ្ដាច់គេដែលបង្កើតឡើងសម្រាប់អស់លោក លោកស្រី។

សូមស្វាគមន៍មកកាន់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី

Mr. CHAU Chung Kai Peter
ស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល
Chief Group

# សារស្វាគមន៍ពី អគ្គនាយកធនាគារ



“ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី គឺធនាគារឯកទេសដែលទើបតែបង្កើតថ្មី ក៏ប៉ុន្តែពោរពេញទៅដោយសក្តានុពលខ្ពស់ ដោយប្រើប្រាស់នូវគំរូអាជីវកម្មផ្តោតសំខាន់ទៅលើ ការបំពេញតម្រូវការអោយបានល្អប្រសើរដល់អតិថិជនទូទៅនៅក្នុងប្រទេសកម្ពុជា”

## សារស្វាគមន៍ពី អគ្គនាយកធនាគារ

**បណ្ឌិត សឿង ម៉ូរ៉ារិទ្ធ**
អគ្គនាយក

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី !សូមស្វាគមន៍!

ការបន្តអនុវត្តយុទ្ធសាស្រ្តរយៈពេលវែងរបស់យើង ដូចជាការយកចិត្តទុកដាក់ខ្លាំងទៅលើការបំពេញចិត្តអតិថិជន ភាពច្នៃប្រឌិត និងភាពខ្លាំង បានធានាថាធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានអនុវត្តយ៉ាងល្អប្រសើរក្នុងឆ្នាំ២០១៧។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បន្តគ្រប់គ្រងសម្រាប់រយៈពេលយូរអង្វែងទៅមុខទៀត ដោយយកអតិថិជនជាចម្បង និងវិនិយោគសម្រាប់ពេលអនាគត ដើម្បីធានាឲ្យបាននូវភាពបត់បែន ភាពខ្លាំង ភាពជោគជ័យ និងការប្រតិបត្តិយ៉ាងខ្លាំងក្លាសម្រាប់ឆ្នាំ២០១៨ និងឆ្នាំបន្តបន្ទាប់ខាងមុខទៀត។ ហើយវាក៏ជាឆ្នាំដែរយើងបន្តអនុវត្ត នូវផែនការអភិវឌ្ឍនខ្លួនពីធនាគារឯកទេស ទៅជាធនាគារពាណិជ្ជ។ សមិទ្ធិផលរបស់យើងក្នុងឆ្នាំនេះអាចកើតមានឡើងបាន តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់ ដែលបានបង្ហាញពីភាពអត់ធន់ ការប្តេជ្ញាចិត្ត និងពលិកម្មក្នុងការងារ និងតាមរយៈការដឹកនាំប្រកបដោយចក្ខុវិស័យ និងទស្សនៈវិស័យ យ៉ាងច្បាស់លាស់របស់ធនាគារ និងដោយភាពជាអ្នកដឹកនាំបែបយុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធិភាព និងការយកចិត្តទុកដាក់ពីសំណាក់ក្រុមប្រឹក្សាភិបាលរបស់ធនាគារផងដែរ។

ដោយសារតែភាពជោគជ័យនៃប្រតិបត្តិការធនាគារ ឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ចេះតែបន្តឥតឈប់ឈរក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានទទួលលិខិតយល់ព្រមជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជា ដែលអនុញ្ញាតឱ្យកម្លាយខ្លួនទៅជា ធនាគារពាណិជ្ជ ដោយស្របទៅតាមលក្ខន្តិកៈចាំបាច់នានា។ ធនាគារឯកទេ ស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី នឹងក្លាយជាធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក. ក្នុងពេលឆាប់ៗនេះដែលនឹងផ្តល់ជូននូវផលិតផល និង សេវាកម្មធនាគារពាណិជ្ជ ជាច្រើនរួមមាន គណនីប្រាក់បញ្ញើ-សន្សំច្រើនប្រភេទផ្សេងៗគ្នា និងឥណទានសំរាប់បុគ្គល ឥណទានសំរាប់ក្រុមហ៊ុន និងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងជាច្រើនទៀតប្រកបដោយលក្ខណៈពិសេសគួរឱ្យទាក់ទាញ និងភាពច្នៃប្រឌិត។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី នឹងក្លាយជាធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក. ដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាដែលមាន Chief Financial Group (Cambodia) Limited ជាម្ចាស់ភាគហ៊ុន និងមានមូលដ្ឋាននៅទីក្រុងហុងកុង បង្កើតឡើងនៅក្រោមច្បាប់ British Virgin Islands។ ទន្ទឹមនឹងនេះផងដែរ ដោយសារតែតម្រូវការកើនឡើងចំពោះសេវាកម្មធនាគារ ដោយហេតុតែមានការចាប់ផ្តើមថ្មីៗនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងការពង្រីកទីផ្សារក្នុងស្រុកយ៉ាងឆាប់រហ័សនេះ វាគឺជាឱកាសដ៏ល្អប្រសើរសម្រាប់ធនាគារនៅទូទាំងអាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ (GMS) ដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួនក្នុងការបម្រើទីផ្សារដ៏ធំនេះ។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានដើរតួនាទីយ៉ាងសំខាន់ដើម្បីជួយសម្រួលដល់ផ្នែកអាជីវកម្ម និងពាណិជ្ជកម្មឆ្លងដែននៅតំបន់មួយក្នុងចំណោមតំបន់រីកលូតលាស់ឆាប់រហ័សនៅក្នុងពិភពលោក។ធនាគារយើងបានអនុវត្តយុទ្ធសាស្រ្តអាជីវកម្មនិងផែនការអភិវឌ្ឍផ្សេងៗដែលមានរយៈពេលវែងដែលបណ្តាលអោយមានគំនិតផ្តួចផ្តើមថ្មីមួយ ដោយរួមបញ្ចូលទាំងការអភិវឌ្ឍយុទ្ធសាស្រ្តដើម្បីរក្សាបាននូវការប្រកួតប្រជែងបន្តទៅមុខទៀត។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានធ្វើការប្តេជ្ញាចិត្តក្នុងការបំពេញ នូវតម្រូវការរបស់អតិថិជន និងជួយពួកគាត់ឲ្យមានភាពជោគជ័យនៅក្នុងវិស័យហិរញ្ញវត្ថុ ហើយធនាគារក៏នៅតែបន្តការប្តេជ្ញាចិត្តយ៉ាងខ្ពស់ ដើម្បីក្លាយជាធនាគារបរទេសមួយដែលប្រកបដោយភាពច្នៃប្រឌិត និងមានប្រសិទ្ធិភាពខ្ពស់បំផុត ដោយផ្តល់នូវការ គាំទ្រយ៉ាងពេញលេញចំពោះសសរស្តម្ភទាំងបួនរបស់ប្រទេសកម្ពុជា ដែរជាកត្តាជំរុញឱ្យមានកំណើនសេដ្ឋកិច្ចរួមមាន ការនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៍ កសិកម្ម និងផ្នែកអចលទ្រព្យ។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ផ្តល់នូវសេវាកម្មមួយដែលស្របទៅនឹងអត្រាស្តង់ដារពិភពលោក ទៅដល់អតិថិជនរបស់ខ្លួននៅប្រទេសកម្ពុជាដែលជាប្រទេសតូចមួយនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ដែលទទួលនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ដោយគ្មានការអាក់ខាន សំរាប់រយៈពេលវែងបំផុតមិនដែរធ្លាប់មាននៅក្នុងកំណត់ត្រាប្រវត្តិសាស្រ្ត។

# សារស្វាគមន៍ពី អគ្គនាយកធនាគារ (ត)

ទាំងនេះក៏ដោយសារតែស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាគ្រឹះមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍ។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានគេព្យាករណ៍ថា នឹងនៅតែមានភាពខ្លាំង និងមានស្ថេរភាពដដែលនៅក្នុងឆ្នាំ២០១៨។ វិស័យធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានរីកលូតលាស់យ៉ាងឆាប់រហ័ស ដោយឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈការកើនឡើងជាលំដាប់ ទៅលើ ទ្រព្យសកម្ម សេវាឥណទាន ប្រាក់បញ្ញើ និង តម្រូវការសម្រាប់សេវាធនាគារផ្សេងទៀត។ ប្រព័ន្ធធនាគារនៅក្នុងប្រទេសនេះបានបន្តធ្វើការអភិវឌ្ឍ និងកែលម្អឡើងជាលំដាប់ ចាប់តាំងពីដំណាក់កាលដំបូងនៃការធ្វើសេរីភាវូបនីយកម្មទ្រង់ទ្រាយធំរបស់ខ្លួន បន្ទាប់ពីការបោះឆ្នោតជាសកលនិងជាលើកដំបូងនៅក្នុងឆ្នាំ១៩៩៣ ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ កត្តានេះ ក៏បានជួយកសាងទំនុកចិត្តដល់សាធារណៈជនកាន់តែខ្លាំងនៅក្នុងវិស័យធនាគារ និងវិសយ័ពាក់ព័ន្ធដ៏ទៃទៀតដែលជំរុញឱ្យមានតម្រូវការកាន់តែខ្ពស់លើសេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មផ្សេងៗទៀតរបស់ធនាគារ។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី កំពុងប្រើប្រាស់គំរូអាជីវកម្មមួយ ដែលបានធ្វើមូលដ្ឋានីយកម្ម ដោយស្របទៅតម្រូវការពិតប្រាកដរបស់អតិថិជននៅក្នុងប្រទេសកម្ពុជា និងតំបន់ដែលស្វែងរកឱកាសវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយសារតែភាពជោគជ័យ នៃប្រតិបត្តិការរបស់ធនាគារ នៅក្នុងឆ្នាំ ២០១៧ យើងកំពុងធ្វើការងារយ៉ាងសកម្ម ដើម្បីអោយប្រសើរបន្ថែមទៀតលើផលិតផល ដែលមានស្រាប់របស់យើងដើម្បីបំពេញនូវតម្រូវការដែលកំពុងកើនឡើងរបស់អតិថិជន។

កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងបរិយាកាសអាជីវកម្មល្អប្រសើរ បានផ្តល់នូវឱកាសជាច្រើនសម្រាប់កំណើននៅក្នុងឧស្សាហកម្ម ទោះបីជាមានការប្រកួតប្រជែងខ្លាំងយ៉ាងណាក៏ដោយ ក៏ប៉ុន្តែធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី ពិតជាមានទំនុកចិត្តនៅក្នុងការចាក់គ្រឹះដ៏រឹងមាំ និងរូបមន្តដ៏ត្រឹមត្រូវក្នុងការធ្វើការជាមួយអតិថិជនសម្រាប់ផលប្រយោជន៍ទៅវិញទៅមក។ ទស្សនៈវិស័យឆ្នាំ២០១៨ ប្រកបទៅដោយគំនិតសុទិដ្ឋិនិយម និងជាមួយការរៀបចំរចនាសម្ព័ន្ធដ៏ល្អប្រសើរ យើងមានជំនឿយ៉ាងមុតមាំថាយុទ្ធសាស្រ្តដ៏មុតស្រួចរបស់យើងរួមបញ្ចូលនូវដំណោះស្រាយរួមរបស់អតិថិជន ទៅនឹងភាពជោគជ័យនៃអាជីវកម្មនឹងនាំអោយធនាគារមានការរីកចំរើនទៅមុខ។

ជួសមុខអោយគណៈគ្រប់គ្រងជាន់ខ្ពស់ នៃធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី ខ្ញុំបាទសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនរបស់យើងទាំងអស់ដែរជ្រើសរើសយកធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី ជាដៃគូពាណិជ្ជកម្មយូរអង្វែង។ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរអរគុណដល់ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ ថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់សម្រាប់ការគាំទ្រដោយគ្មានការងាកេរបស់ពួកគេ ដែលបានផ្តល់ជាលទ្ធផលនៅក្នុងការទទួលបានជោគជ័យរបស់ធនាគារនៅក្នុងឆ្នាំ២០១៧ ហើយការប្រឹងប្រែង និងប្តេជ្ញាចិត្តរបស់ពួកយើងនឹងបន្តនាំយកភាពជោគជ័យទៅដល់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុីជាថ្មីម្តងទៀតនៅក្នុងឆ្នាំ២០១៨ និងឆ្នាំបន្តបន្ទាប់ទៀត ។ ខ្ញុំបាទពិតជាមានមោទនភាពខ្លាំងណាស់ដោយមានសហសេវិក ប្រកបដោយជំនាញវិជ្ជាជីវៈច្បាស់លាស់ និងមានការប្តេជ្ញាចិត្តខ្ពស់ ដែលបាននឹងកំពុងជំរុញយ៉ាងសកម្មនូវកេរ្តិ៍ឈ្មោះ ក៏ដូចជាអនាគតរបស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី នៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំកំពុងធ្វើការយ៉ាងសកម្មប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ក្នុងការធ្វើអោយធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី ឈានទៅកាន់ចំនុចកំពូលថ្មីមួយ។

យើងខ្ញុំរង់ចាំស្វាគមន៍ និងផ្តល់ការបម្រើដល់ល្អបំផុតដល់អស់លោកអ្នកជានិច្ច។

ដោយការគោរពដ៏ស្មោះស្ម័គ្រពីខ្ញុំ

**បណ្ឌិត សឿង ម៉ូរ៉ារិទ្ធ**
អគ្គនាយក
ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលសុី

# ក្រុមប្រឹក្សាភិបាល



## Mr. CHAU Chung Kai Peter

### ស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល, Chief Group

Mr. Chau Chung Kai Peter, គឺជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាល Chief Group ហើយគាត់ក៏ជាសហគ្រិនជោគជ័យមួយរូបនៅក្នុងទីក្នុងហុងកុង ដែលបានបង្កើតឡើងនូវសហគ្រាសរបស់គាត់ពីដំបូង។ លោក CHAU បានកើតនៅក្នុងឆ្នាំ១៩៣៩ នៅក្នុងទីក្រុងចៅស៊ូ (Chaozhou) ប្រទេសចិន។ លោក CHAU បានចូលបំរើការងារនៅក្នុងឧស្សាហកម្មធនាគារហុងកុងនៅក្នុងឆ្នាំ ១៩៥៨។ លោក CHAU គឺជានាយកប្រតិបត្តិជាន់ខ្ពស់របស់ធនាគារ Chong Hing ពីឆ្នាំ ១៩៥៩ ដល់ ១៩៦២ និងជានាយកប្រតិបត្តិរបស់ធនាគារបាងកកពី ឆ្នាំ១៩៦២ ដល់ ១៩៧០។ លោក CHAU មានបទពីសោធន៍យ៉ាងច្រើនជាមួយធនាគារពាណិជ្ជក្នុងការបង្កើតនូវផលិតផលដែលប្រកបដោយភាពឆ្នៃប្រឌិតឈានមុខគេ និង ធ្វើប្រតិបត្តិការណ៍ផ្នែកធនាគារដ៏ល្អប្រសើរ ក្នុងកំឡុងពេលការអភិវឌ្ឍន៍វិស័យឧស្សាហកម្មធនាគារ នៅទីក្រុងហុកុង។ លោក CHAU បានបង្កើតនូវក្រុមហ៊ុនផ្ទាល់ខ្លួនរបស់លោកនៅក្នុងឆ្នាំ ១៩៧៩ ដែលមានឈ្មោះថា "Chief Investment Co."។ លោកបានទទួលយកនូវបទពិសោធន៍ដ៏មានតំលៃ (ដោយការចាប់ផ្តើមដាក់បង្ហាញទៅដល់ទីផ្សារមូលធនជាសកល និងឧស្សាហកម្មហិរញ្ញវត្ថុ) នៅក្នុងពាក់កណ្តាលសតវត្សរ៍ចុងក្រោយ។ ជំនឿ នៃសុចរិតភាព និង ភាពស្មោះត្រង់ គឺជាព្រលឹងដ៏សំខាន់មួយដែលលោក CHAU បន្តបង្កើតអស់រយះពេលជាង៣០ឆ្នាំ នៅពេលដែលលោកប្រតិបត្តិនៅក្នុងក្រុមហ៊ុននេះ។ រហូតមកដល់ពេលបច្ចុប្បន្ន Chief Group គឺជាក្រុមហ៊ុនមួយ ក្នុងចំនោម អន្តរការីមូលបត្រដ៏ធំជាងគេនៅក្នុងទីក្រុងហុងកុង ដែលមាន ចំនួនសាខា និង ជាក្រុមហ៊ុននាំមុខគេមួយនៅក្នុងវិស័យឧស្សាហកម្មសំរាប់ សេវា និងផលិតផលហិរញ្ញវត្ថុច្រើនប្រភេទ។ លោក CHAU យកចិត្តទុកដាក់យ៉ាងសកម្មផងដែរ នៅក្នុងសកម្មភាព សប្បុរសធម៌ ដែលគាត់ជឿជាក់ថា ការអប់រំគឺជាមូលដ្ឋាន នៃការកសាងជាតិ។ ការចាប់ផ្តើមពីឆ្នាំ ២០០៦, លោក CHAU បានផ្តល់ការបរិច្ចាគបន្តបន្ទាប់ជាបុគ្គល និង ស្ថាបនិកក្រុមហ៊ុន ក្នុងការកសាងសាលារៀន នៅក្នុងតំបន់ដាច់ស្រយាលជាច្រើននៃប្រទេសចិន រួមទាំងសាលាបឋមសិក្សាចំនួន៥០សាលា និង អនុវិទ្យាល័យចំនួន២សាលា។



## Ms. NG Siu Mui, Fion

### អភិបាល
### ប្រធាន គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
### សមាជិក គណៈកម្មាធិការសវនកម្មផ្ទៃក្នុង
### សមាជិក គណៈកម្មាធិការធនធានមនុស្ស

*ការសិក្សា*

- បរិញ្ញាប័ត្រជាន់ខ្ពស់គ្រប់គ្រងធុរកិច្ច នៅសាកលវិទ្យាល័យហុងកុង ទីក្រុងហុងកុង។
- សញ្ញាប័ត្រវិជ្ជាជីវៈ អភិបាលកិច្ចនិងដឹកនាំសាជីវកម្ម ក្នុងទីក្រុងហុងកុង។

*បទពិសោធន៍ការងារ*

- អគ្គនាយិការង Chief Holdings (H.K.) Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា និងមន្ត្រីទទួលខុសត្រូវ Chief Security Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- មន្ត្រីទទួលខុសត្រូវ Chief Commodities Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា Chief Great China Assets Management Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា Chief Financial Services Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។



## Mr. LAM Wai Chuen, Patrick

អភិបាល

សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង

*ការសិក្សា*

- Certified Public Accountant, HKICPA, Hong Kong
- សមាជិកសមាគមន៍, ACCA

*បទពិសោធន៍ការងារ*

- អ្នកត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Chief Holdings Ltd ទីក្រុងហុងកុង(បច្ចុប្បន្ន)។
- ប្រធានសវនកម្ម របស់ក្រុមហ៊ុន Kreston CAC CPA Limited ។



## Mr. YE Haiya, Michael

អភិបាល

សមាជិក គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

សមាជិក គណៈកម្មាធិការសវនកម្មផ្ទៃក្នុង

សមាជិក គណៈកម្មាធិការធនធានមនុស្ស

*ការសិក្សា*

- បរិញ្ញាបត្រវិទ្យាសាស្ត្រនៅសាកលវិទ្យាល័យហុងកុង ទីក្រុងហុងកុង។

*បទពិសោធន៍ការងារ*

- នាយកផ្នែក Investment Sales Division, Chief Holdings Limited ទីក្រុងហុងកុង(បច្ចុប្បន្ន)។
- មន្ត្រីទទួលខុសត្រូវ Chief Securities Limited (បច្ចុប្បន្ន)។
- នាយក Chief Financial Services Limited (បច្ចុប្បន្ន)។
- មន្ត្រីទទួលខុសត្រូវ Chief Great China Assets Management Limited (បច្ចុប្បន្ន)។



## Mr. CHAN Kwok Cheung

នាយកក្រុមប្រឹក្សាភិបាលឯករាជ្យ

ប្រធាន គណៈកម្មាធិការសវនកម្មផ្ទៃក្នុង

*ការសិក្សា*

- សមាជិកសមាគមន៍, HKICPA ទីក្រុងហុងកុង។
- សមាជិកសមាគមន៍, ACCA។

*បទពិសោធន៍ការងារ*

- នាយកក្រុមហ៊ុន Kreston CAC CPA Limited (បច្ចុប្បន្ន)។

# អគ្គនាយក



## បណ្ឌិត សៀង ម៉ូរ៉ារិទ្ធ

អគ្គនាយក
ប្រធានគណៈកម្មាធិការធនធានមនុស្ស
អ្នកតំណាងឲ្យធនាគារឯកទេស ដែលបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាលរបស់សមាគមធនាគារនៅកម្ពុជា

*ការសិក្សា*

- បណ្ឌិត គ្រប់គ្រងពាណិជ្ជកម្ម ឯកទេសហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង។
- អត្ថបទស្រាវជ្រាវលើ "ការវាយតំលៃនៃការអនុវត្ត (គុណភាព និងសេវា) SERVQUAL នៅក្នុង វិស័យធនាគាររបស់កម្ពុជា" នៅមជ្ឍមណ្ឌលសម្រាប់ការសិក្សាអាស៊ាននៃសាកលវិទ្យាល័យ Antwerp ប្រទេសបែលហ្ស៊ិកឆ្នាំ២០១២។វិស័យធនាគាររបស់កម្ពុជា" នៅមជ្ឍមណ្ឌលសម្រាប់ ការសិក្សាអាស៊ាននៃសាកលវិទ្យាល័យ Antwerp ប្រទេសបែលហ្ស៊ិកឆ្នាំ ២០១២។
- អនុបណ្ឌិត នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅរាជធានីភ្នំពេញ។
- សញ្ញាបត្រអាជីពជំនាញខាងអភិវឌ្ឍន៍អ្នកដឹកនាំល្អ ពី Harvard Business School, Boston, USA ។

*បទពិសោធន៍ការងារ*

- នាយកជាន់ខ្ពស់ និងប្រតិភូបុគ្គលិក នៅធនាគារ Kookmin រាជធានី ភ្នំពេញ។
- នាយកឥណទាន នៅធនាគារ Kookmin រាជធានីភ្នំពេញ។
- ប្រធានឥណទាន (ទីស្នាការកណ្ដាល) នៅធនាគារ Angkor Capital រាជាធានីភ្នំពេញ។
- មន្ត្រីឥណទានជាន់ខ្ពស់នៅ Cambodian Public Bank រាជាធានីភ្នំពញ។
- មន្ត្រីឥណទាន នៅធនាគារ Canadia រាជាធានីភ្នំពេញ។
- សាស្ត្រាចារ្យ ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង និង សាកលវិទ្យាល័យ ដ៏ទៃទៀត(បច្ចុប្បន្ន)។

# រចនាសម្ព័ន្ធ

## ក្រុមប្រឹក្សាភិបាល



**Mr. CHAU Chung Kai Peter**

Chairman of the Board of Director



**Ms. NG Siu Mui**

Director

Chairwoman, Risk Management Committee
Chairwoman, Risk Management Committee
Member, Human Resource Committee



**Mr. LAM Wai Chuen**

Director

Member, Internal Audit Committee



**Mr. YE Haiya**

Director

Member, Risk Management Committee
Member, Internal Audit Committee
Member, Human Resource Committee



**Mr. CHAN Kwok Cheung**

Independent Non-Executive Director

Chairman, Internal Audit Committee

# រចនាសម្ព័ន្ធ

## គណៈគ្រប់គ្រង



បណ្ឌិត សឿង ម៉ូរ៉ារិទ្ធ
អគ្គនាយក



លោក នួន អង្គារឫទ្ធិ
នាយកផ្នែកប្រតិបត្តិការ



លោក វ៉ាន់ តុលា
ប្រធានផ្នែករដ្ឋបាល
និងធនធានមនុស្ស



លោកស្រី សោម សុជាតិ
ប្រធានផ្នែកគណនេយ្យ



លោក ធុល កុសល
ប្រធានផ្នែកនីតិកម្ម
និងប្រតិបត្តិតាម



លោក ឈិត វណ្ណរចនារដ្ឋ
នាយកសាខា



លោក ទី សុចិត្រា
ប្រធានផ្នែកឥណទាន



ម៉ម ចាន់ដារ៉ា
នាយកផ្នែកសវនកម្ម



វ៉ាន់ សីហា
ប្រធានផ្នែកហិរញ្ញប្បទាន
ពាណិជ្ជកម្ម



លោក សុខ សំណាង
ប្រធានផ្នែកទីផ្សារ
និងការលក់



លោក យួន រិទ្ធ
ប្រធានផ្នែកព័ត៌មានវិទ្យា



ម៉ូនីស្វាមី គីសស័រ គូម៉ា
អ្នកវិភាគប្រព័ន្ធព័ត៌មានវិទ្យាជាន់ខ្ពស់

# ព័ត៌មានសង្ខេបអំពីធនាគារ




| | |
|---|---|
| ឈ្មោះរបស់ធនាគារ | ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី |
| កាលបរិច្ឆេទនៃការបង្កើតធនាគារ | ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ |
| លេខនៃការចុះបញ្ជី | ធឯ-១១ |
| អាសយដ្ឋាន ការិយាល័យកណ្ដាល | ផ្ទះលេខ សេ ០១ ផ្លូវអ៊ែ ១១ កែងនឹងផ្លូវ៧០ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
| តំលើងដើមទុន | US$38.8 Million |
| ចំនួនបុគ្គលិក | ៥២ |

| | ឈ្មោះ | ចំនួនភាគហ៊ុនដែរបានកាន់កាប់ | ភាគរយនៃភាគហ៊ុនដែរបានកាន់កាប់(%) |
|---|---|---|---|
| ម្ចាស់ភាគហ៊ុន | Chief Financial Group (Cambodia) Limited. | | ១០០% |

| | |
|---|---|
| ក្រុមហ៊ុនសាច់ញាតិ | ■ Chief Holdings (H.K.) Ltd.<br>■ Chief Securities Ltd.<br>■ Chief Commodities Ltd.<br>■ Chief Financial Capital Ltd.<br>■ Chief Financial Services Ltd.<br>■ Chief Great China Assets Management Ltd. |
| សវនករ | Deloitte (Cambodia) Co., Ltd. |

# ផលិតផល និង សេវា

*ដើម្បីបំពេញនូវតម្រូវការកើនឡើងរបស់អតិថិជន ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានធ្វើការយ៉ាងសកម្ម ក្នុងការធ្វើអោយប្រសើរឡើងបន្ថែមទៀត ចំពោះ ផលិតផលដែរមានស្រាប់របស់យើង និង ធ្វើការផ្តល់ជូននូវផលិតផលជា ឯកទេសពិតប្រាកដប្រកបដោយលក្ខណៈដ៏គួរអោយទាក់ទាញ និង ថ្លៃប្រឌិត ដែរទាំងនោះគឺសាកសមបំផុតសំរាប់អតិថិជនដែលមានតំរូវការហិរញ្ញប្បទានអាជីវកម្មខ្នាតតូច កសិដ្ឋានឥណទានផ្ទាល់ខ្លួន និង ក្រុមហ៊ុន។ល។*

## ឥណទានសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន





ឥណទានទិញគេហដ្ឋាន



ឥណទានទិញរថយន្ត



ឥណទានទិញម៉ូតូ

# ឥណទាន អាជីវកម្ម





ឥណទានអាជីវកម្មខ្នាតតូច និងតូចបំផុត



ឥណទានអាជីវកម្មខ្នាតមធ្យម



ឥណទានអាជីវកម្មខ្នាតធំ

# ព័ត៌មានសង្ខេបអំពី CHIEF HOLDINGS




លោក Chau Chung Kai Peter គឺជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនChief Cambodia Holding Ltd និងChief Holding (H.K) Ltd ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៩ នៅក្នុងទីក្រុងហុងកុង។ ជាច្រើនទសវត្សន៍មកនេះក្រុមហ៊ុន Chief Group បានចូលរួមនៅ ក្នុងស្ថាប័នហិរញ្ញវត្ថុ ដ៏ទូលំទូលាយមួយ ជាមួយនឹងសេវាកម្ម និងផលិតផលច្រើនប្រភេទផ្សេងៗគ្នា។យើងគឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុននាំមុខគេក្នុង វិស័យឧស្សាហកម្ម អន្តរការីហិរញ្ញវត្ថុ របស់ទីក្រុងហុងកុង ដែរបានកាន់កាប់ដោយមោទនភាពនូវបណ្តាញសេវាសាខាធំជាងគេបង្អស់។

## បេសកកម្មរបស់យើង

យើងបានប្តេជ្ញាដើម្បីបំរើអតិថិជនរបស់យើងជាមួយឥរិយាបទប្រកបដោយសុចរឹតភាព និងគុណភាព។ ទាំងនោះហើយដែលបានបង្កើតនូវទស្សនះអាជីវកម្មតែមួយ (ទីណាមានមនុស្ស ទីនោះមាន ឈីហ្វ, The Chief Way) ដែរជាវិធីសាស្ត្រគ្រប់គ្រងទ្រព្យសម្បត្តិអោយប្រសើរឡើងតែមួយគត់។ ទីណាមានមនុស្ស ទីនោះមាន ឈីហ្វ, The Chief Way នាំមកនូវភាពជឿជាក់លើមនោគមវិជ្ជាអាជីវកម្មរបស់យើង និងភាពស្មោះត្រង់របស់អតិថិជន និង ដៃគូរអាជីវកម្ម។ យើងស្វែងរកភាពរីកចំរើនទាំងអស់គ្នា ជាមួយអតិថិជន និង ដៃគូរអាជីវកម្មរបស់យើង។

## ទស្សនះវិស័យរបស់យើង

មូលដ្ឋានរឹងមាំដែ លបានចាក់ឬសនៅក្នុងទីក្រុងហុងកុង យើងបានពង្រីកនូវព្រំដែនអាជីវកម្មរបស់យើងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការដាក់ទីតាំងនូវចំកណ្តាលបេះដូងនៃឥណ្ឌូចិន ដូចជាប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍យ៉ាងរហ័ស គឺជាមជ្ឈមណ្ឌលដំបូងនៃបណ្តាញសេវារ របស់យើង នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ យើងផ្តល់នូវភាពជំនាញទៅអោយ អតិថិជនរបស់យើង និងចែករំលែកនូវសមិទ្ធិផលជាមួយនឹងបុគ្គលិកក្នុងស្រុកយើងនៅក្នុងប្រទេសកម្ពុជា។

ដូចជាឧត្តមភាពសេវាកម្ម តែងតែជាការស្វែងរកតំបូងបង្អស់របស់យើង យើងបានផ្តល់នូវចំនុចអាទិភាព ដើម្បីរក្សានូវការលើកកម្ពស់ សេវាកម្មតាមរយះ វគ្គបណ្តុះបណ្តាលបុគ្គលិក ការរួមបញ្ជូលខាងបច្ចេកវិទ្យា និង ភាពផ្សេងៗគ្នានៃ ផលិតផល។ យើងចង់ក្លាយជាធនាគារ គំរូនៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុ។

# ព័ត៌មានសង្ខេបអំពី
# ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី



ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី គឺជាធនាគារក្នុងស្រុក ដែលបានបង្កើត ឡើងនៅចុងឆ្នាំ២០១៣ ជាមួយនឹងដើមទុនចុះបញ្ជីថ្មីៗ ចំនួន៣៨,៨លានដុល្លារសហរដ្ឋអាមេរិក ហើយនឹងតម្លើងដើមទុនចុះបញ្ជី របស់ខ្លួនរហូតដល់ ៧៥លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំនេះផងដែរ ។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានធ្វើការប្តេជ្ញាចិត្ត ដើម្បីក្លាយជាធនាគារឯកទេសមួយប្រកបដោយភាពច្នៃប្រឌិត និងមានប្រសិទ្ធិភាពខ្ពស់បំផុត ដោយផ្តល់នូវការគាំទ្រយ៉ាងពេញលេញចំពោះសសរស្តម្ភទាំងបួននៃកំណើនសេដ្ឋកិច្ចកម្ពុជា ដូចជា៖ វិស័យនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៍ វិស័យកសិកម្ម និង វិស័យអចលនទ្រព្យ។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ផ្តល់នូវ ផលិតផល និងសេវាឥណទានល្អឥតខ្ចោះរួមមាន៖ ឥណទានទិញម៉ូតូ ឥណទានទិញឡាន ឥណទានទិញគេហដ្ឋាន ឥណទានអាជីវកម្មខ្នាតតូចបំផុត ឥណទានអាជីវកម្មខ្នាតតូច ឥណទានអាជីវកម្មខ្នាតមធ្យម ឥណទានអាជីវកម្មខ្នាតធំ និងឥណទានសម្រាប់ក្រុមហ៊ុន ទៅអោយអតិថិជនរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសតូចមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលបាននូវ អត្រាកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ដោយគ្មានការអាក់ខាន សម្រាប់រយៈពេលវែងបំផុត មិនដែរធ្លាប់មាននៅក្នុងកំណត់ត្រាប្រវត្តិសាស្រ្ត ដោយសារតែមានស្ថេរភាពទាំង នយោបាយ និងម៉ាក្រូសេដ្ឋកិច្ច។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ជាធនាគារឯកទេស ដែលទើបតែបង្កើតថ្មី ក៏ប៉ុន្តែពោរពេញដោយសក្តានុពលខ្ពស់ ដោយប្រើប្រាស់នូវគំរូអាជីវកម្មផ្តោតសំខាន់ទៅលើ ការបំពេញតម្រូវការអោយបានល្អប្រសើរបំផុតដល់អតិថិជនទូទៅ នៅក្នុងប្រទេសកម្ពុជានិងតំបន់ដែលបានស្វែងរកឱកាសវិនិយោគនៅក្នុងរាជាណាចក្រកម្ពុជា។ ដោយសារតែ ភាពជោគជ័យនៃប្រតិបត្តិការធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ចេះតែបន្តឥតឈប់ឈរក្នុង រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះធនាគារ ឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បាន ទទួលលិខិតយល់ព្រមជាគោលការណ៍ ពីធនាគារជាតិនៃកម្ពុជានៅ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ ដែលអនុញ្ញាតឱ្យកម្លាយខ្លួនទៅជាធនាគារពាណិជ្ជ ដោយត្រូវបំពេញស្របទៅតាម លក្ខខណ្ឌចាំបាច់នានាមួយចំនួនរបស់ធនាគារជាតិនៃកម្ពុជា។

ធនាគារ ឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី នឹងក្លាយជាធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក. ក្នុងពេលអនាគត ដែលនឹងផ្តល់ជូននូវផលិតផល និង សេវាកម្ម ធនាគារពាណិជ្ជជាច្រើន រួមមាន គណនីប្រាក់បញ្ញើ-សន្សំច្រើនប្រភេទផ្សេងៗគ្នា និង ឥណទានសំរាប់បុគ្គល ឥណទានសំរាប់ក្រុមហ៊ុន និង សេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងជាច្រើនទៀត ប្រកបដោយលក្ខណៈ ពិសេសគួរឱ្យទាក់ទាញនិងភាពច្នៃប្រឌិត។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី នឹងក្លាយជាធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក. ដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាដែលមាន Chief Financial Group (Cambodia) Limited ម្ចាស់ភាគហ៊ុនជារបស់ឯកជន និងមានមូលដ្ឋាននៅ ទីក្រុងហុងកុង បង្កើតឡើងនៅក្រោមច្បាប់ British Virgin Islands។

## ចក្ខុវិស័យរបស់យើង

យើងប្តេជ្ញាបំពេញនូវតម្រូវការអតិថិជន និងជួយជ្រោមជ្រែងពួកគេអោយទទួលបានជោគជ័យ ខាងផ្នែកហិរញ្ញវត្ថុ។

## បេសកកម្មរបស់យើង

- ក្លាយជាធនាគារដ៏ធំ ដែលផ្តល់នូវសេវាកម្មសម្បូរបែប ជាមួយនឹងបណ្តាញសាខាធំ ជាងគេ
- ជា ធនាគារដែលជាជម្រើសរបស់អតិថិជនទី១ ដែរផ្តល់នូវបទពិសោធន៍ដ៏គួរអោយទាក់ទាញ
- ជា ធនាគារបរទេស ដែរប្រកបដោយប្រសិទ្ធិភាព និងការច្នៃប្រឌិតខ្ពស់ ដែរមានការធានា និងការផ្តល់សេវាកម្មប្រកបដោយភាពល្អឥតខ្ចោះ
- ធានានូវការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ និង គោរពប្រតិបត្តិទៅតាមច្បាប់ទាំងឡាយដែលយើងបានធ្វើ

## គោលដៅរបស់យើង

គោលដៅរបស់យើ ង គឺ ក៏សាងនូវទំនាក់ទំនងជាមួយអតិថិជនរបស់យើង អោយកាន់តែទូលំទូលាយ ស្និតស្នាល និង យូរអង្វែង ហើយយើងរង់ចាំជួយពួកគេ គ្រប់ជំហ៊ាន ដើម្បីអោយមុខ ជំនួញរបស់ពួកគេឆ្ពោះទៅរកភាពមានបាន និងផ្តល់អោយនូវគុណតម្លៃដែរមានរយៈពេលវែងសំរាប់ម្ចាស់ភាគហ៊ុន។

## ទស្សនវិជ្ជារបស់យើង

- រក្សានូវ ភាពស្មោះត្រង់ និង វិជ្ជាជីវៈ អោយខ្ពស់បំផុត
- ឈានមុខគេ តាមរយៈគំនិតច្នៃប្រឌិត និងការបង្កើតថ្មី នៃផលិតផលនិងសេវាកម្ម
- ភ្ជាប់ទំនាក់ទំនង និង បំរើអតិថិជន យ៉ាងសកម្មនិងអស់ពីដួងចិត្ត
- ចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពសង្គម

# វប្បធម៌ការងារ

ដោយបង្កើតនូវការងារជាក្រុមក្នុងចំណោមបុគ្គលិករបស់យើង យើងលើកទឹកចិត្តដល់បុគ្គលិកដែលមានបំណងចង់សិក្សា នឹងមានចក្ខុវិស័យឆ្ពោះទៅការងាររបស់ពួកគេ។ ពួកគេគឺជាកត្តាដ៏សំខាន់ ដើម្បីជោគជ័យរបស់ពួកគេ នៅក្នុងការសំរេចបានគោលដៅ និង ការអភិវឌ្ឍន៍នៃទំនាក់ទំនងយ៉ាងរឹងមាំនៅក្នុងរង្វង់ការងាររបស់ពួកគេ។ម្យ៉ាងវិញទៀតយើងក៏យកចិត្តទុក្ខដាក់ផងដែរទៅលើ ក្រមសីលធម៌វិជ្ជាជីវៈអោយមានកំរិត ខ្ពស់។ សុចរិតភាព ការប្រុងប្រយ័ត្ន និង តម្លាភាព គឺជាមូលដ្ឋានស្នូល នៃវប្បធម៌ការងារ របស់យើង។

ការចែករំលែកនូវបច្ចេកទេស និង វគ្គបណ្តុះបណ្តាល ត្រូវបានរៀបចំសំរាប់គ្រប់បុគ្គលិកទាំងអស់របស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ជាទៀងទាត់។ ទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ នូវគុណភាព និង ប្រសិទ្ធភាព នៃសេវារបស់យើង។ ក្រុមបុគ្គលិករបស់យើងត្រូវបានរក្សានូវការបោះជំហ៊ានឆ្ពោះទៅមុខ ជាមួយពេលវេលា។










# ការបំពេញចិត្តអតិថិជន



“ យើងមានគោលបំណងដើម្បីផ្តល់នូវគុណភាពសេវាដ៏ប្រសើរជាងគេ និងការបំពេញចិត្តអតិថិជនអោយប្រសើរឡើង។ ”



## ការបំពេញចិត្តអតិថិជន

យើងមានគោលបំណងដើម្បីផ្តល់នូវគុណភាពសេវាដ៏ប្រសើរជាងគេ និងការបំពេញចិត្តអតិថិជនអោយប្រសើរឡើង។ គុណភាពសេវាដ៏ប្រសើរជាងគេ អាចបង្កើតបន្ថែមទៀតនូវភាពស្មោះត្រង់របស់អតិថិជន នាំមកនូវឱកាសសំរាប់ការលក់ផលិតផលចំរុះនិងអតិថិជនដែលផ្សព្វផ្សាយអោយប្រើប្រាសនូវសេវាកម្មរបស់យើងផងដែរ។ កេរ្តិ៍ឈ្មោះរបស់សហគ្រាស គឺ ត្រូវផ្តើមឡើងពីការពេញចិត្តខ្ពស់ ពីសំណាក់អតិថិជន។

ធនាគារឯកទេស ឈីហួ (ខេមបូឌា) ភីអិលស៊ី ផ្តោតទៅលើ សុចរឹតភាពអាជីវកម្ម និង យើងធ្វើការយ៉ាងយកចិត្តទុកដាក់ជាមួយអតិថិជនរបស់យើង បុគ្គលិក របស់យើង និង សង្គមរបស់យើងដើម្បីអនាគតដ៏ល្អប្រសើរខាងមុខ។ តាមរយៈសេវាប្រកបដោយ វិជ្ជាជីវៈនិង សីលធម៌ យើងបង្កើត នូវភាពជឿជាក់ ទៅវិញទៅមក និង ដៃគូរអាជីវកម្មរយៈពេលវែងជាមួយអតិថិជន របស់យើង។

យើងបានប្រគល់ជូននូវការបែងចែកជំនាញវិជ្ជាជីវៈសំរាប់គ្រប់ៗគ្នា និងគ្រប់អតិថិជន ដើម្បីកាន់កាប់នូវ ប្រតិបត្តិការណ៍ធនាគារពាណិជ្ជនៅក្នុងធនាគារឯកទេស ឈីហួ (ខេមបូឌា) ភីអិលស៊ី។ ព័ត៌មានអ្វីទាំងអស់ដែលបានផ្តល់ដោយ ធនាគារឯកទេស ឈីហួ (ខេមបូឌា) ភីអិលស៊ី គឺជាការកើនឡើងរហូតដល់ចំនុចគួរ អោយកត់ សម្គាល់ និងចម្ងល់របស់អតិថិជនទាំងអស់ត្រូវបានបកស្រាយយ៉ាងច្បាស់លាស់។ ចំនុចពិសេសៗដ៏ទៃទៀតរបស់ធនាគារឯកទេស ឈីហួ (ខេមបូឌា) ភីអិលស៊ី គឺជាការតាមដានដ៏ជាប់លាប់ ចំពោះសំណើរអតិថិជនរបស់យើង ដើម្បីឆ្លើយតបទៅនិងតំរូវការ និង ការចង់បានរបស់ពួកគេ។ ដូចគ្នានោះផងដែរ យើងស្វែងរកជាទៀងទាត់នូវយោបល់ត្រឡប់របស់អតិថិជន ដើម្បីដឹងនូវឱកាសអភិវឌ្ឍន៍ផលិតផល និងសេវា ហើយ ដើម្បីប្រាប់ពួកយើងអោយប្រុងប្រយ័ត្ន ទៅនឹងការរីកចំរើនប្រកបដោយសក្តានុពល។ យើងមានវិធីសាស្រ្តជាច្រើន ដើម្បីប្រមូលផ្តុំ ព័ត៌មានពីអតិថិជន តាមរយៈទូរស័ព្ទ ការស្ទង់មតិ ការបំពេញចិត្តរបស់អតិថិជន និង មតិយោបល់ដែលសរសេរដោយអតិថិជន។ យើងនឹងពិនិត្យមើលទៅលើមតិយោបល់របស់អតិថិជនម្តងមួយៗ និង យកនូវតំរូវការសកម្មភាពសមស្របណាមួយ ដើម្បីធ្វើការដោះស្រាយទៅ តាមស្ថានភាពផ្សេងៗគ្នា។

# ទិសដៅយុទ្ធសាស្ត្រ ឆ្នាំ២០១៧

*ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានធ្វើការប្តេជ្ញាចិត្ត ក្នុងការបំពេញនូវ តម្រូវការរបស់អតិថិជននិងជួយពួកគាត់ឲ្យមានភាពជោគជ័យនៅក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំង ក្លាយជាធនាគារ បរទេសក្នុងស្រុក ដែលប្រកបដោយភាព ច្នៃប្រឌិត និងមាន ប្រសិទ្ធិភាពខ្ពស់បំផុតនៅក្នុងប្រទេស កម្ពុជា។ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ផ្តល់នូវការគាំទ្រយ៉ាងខ្លាំងដល់សរសរ គ្រឹះសេដ្ឋកិច្ចទាំងបួន ដែលជាកត្តាជំរុញ អោយ វិស័យសេដ្ឋកិច្ចរីកចំរើនខ្លាំងនៅប្រទេសកម្ពុជារួមមាន៖ ការនាំចេញសម្លៀក បំពាក់វិស័យទេសចរណ៍ កសិកម្ម និងផ្នែកអចលទ្រព្យ។*

## ក. យុទ្ធសាស្ត្រទីផ្សារ

យុទ្ធសាស្ត្រអាទិភាពដំបូងគេ របស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី គឺដើម្បីបំពេញចិត្តអតិថិជនដែលមានស្រាប់របស់ខ្លួន ដោយផ្តល់អោយនូវផលិតផលដែលបានចម្រាញ់អោយកាន់តែប្រសើរឡើង ជាមួយនឹងអត្រាការប្រាក់ប្រកួតប្រជែងលើទីផ្សារ ដោយស្រប ទៅតាមការវិវត្តនូវតំរូវការចាំបាច់របស់ពួកគេ ទាំងនេះបានបង្ហាញជាភស្តុតាង តាមរយៈ កំណើនតំរូវការជាមូលដ្ឋាន របស់អតិថិជន និង កំណើនជារៀងរាល់ថ្ងៃនៃ គុណភាពឥណទានសរុបរបស់យើង (គ្មានឥណទានដែរខូច រហូតដល់ពេលបច្ចុប្បន្ន)។

យុទ្ធសាស្ត្រអាទិភាពទីពីរគឺដើម្បីទាញយកអតិថិជនថ្មីតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែរមានប្រជាប្រិយភាព ក្នុងគោលបំណងដើម្បីបង្កើននូវចំនួនអតិថិជនថ្មីៗបន្ថែមទៀត ចូលទៅក្នុងវដ្តនៃការរីកចំរើនក្នុងពេលបច្ចុប្បន្នដែលមានស្រាប់ ដោយធ្វើការពង្រីកនូវបណ្តាញសាខាជាច្រើន ទៅទីកន្លែងដែលមានសក្តានុពល នៅក្នុងរាជធានីភ្នំពេញ ក្នុងខណៈពេលដែលចាប់ផ្តើមនូវការប្តេជ្ញាចិត្តដើម្បីផ្តល់នូវការជឿជាក់ ការច្នៃប្រឌិតសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពរាក់ទាក់ ការប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប និង ផ្តោតទៅលើ ការធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់ តាយរយៈការអភិវឌ្ឍនបុគ្គលិករបស់យើង និង ការទទួលយកនូវជំនាញការចាំបាច់មួយដើម្បីចាប់យកអត្ថប្រយោជន៍ប្រៀបធៀបពីគូរប្រកួតប្រជែងរបស់យើង។

បន្ទាប់មកទៀត យើងកំពុងមានផែនការណ៍ពង្រីក ទៅកាន់ខេត្តក្រុងដែលជឿជាក់ថាមាន សក្តានុពលថ្មី ដូចជា ក្រុងព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និង ខេត្តបាត់ដំបង។ នៅក្នុងរយះពេល១០ឆ្នាំ យើងជឿជាក់ថា អាចពង្រីកបន្ថែមទៀតជាមួយប្រតិបត្តិការណ៍សាខា នៅក្នុង ខេត្តកណ្តាល ខេត្តពោធិសាត់ ខេត្តព្រៃវែង និង ខេត្តតាកែវ។ វាគឺជាបំណងរបស់យើងផងដែរ ដើម្បីបង្កើតនូវការិយាល័យតំណាង (និង សាខាបន្តបន្ទាប់) នៅក្នុងទីក្រុងហុងកុង នៅពេលសមរម្យណាមួយដើម្បីគាំទ្រអោយប្រសើរឡើងនូវអាជីវកម្មអន្តរជាតិរបស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី។

## ខ- ការកំណត់ទីផ្សារគោលដៅ

ធនាគារឯកទេស ឈី ហ្វ (ខេម បូឌា) ភីអិលស៊ី សម្លឹងមើលឃើញនូវបរិយាកាសសេដ្ឋកិច្ច និង សង្គម មានភាពវិជ្ជមាន ដើម្បីពង្រីកនូវសកម្មភាពរបស់ខ្លួននៅក្នុងបីឆ្នាំបន្ទាប់។ធនាគារ បានអភិវឌ្ឍន៍នូវបែបបទគ្រោងការគ្រប់គ្រងដើមទុនផ្លូវការមួយដោយមានគោលដៅដែលបានកំណត់យ៉ាងច្បាស់លាស់ដើម្បីរក្សានូវកំរិតសមស្របនៃដើមទុន។ ទាំងនេះធានាឱកាស គ្រប់គ្រាន់សម្រាប់ការពង្រីកអាជីវកម្មនាពេលអនាគត។

ធនាគារ បានកំណត់យកនូវទីតាំង ដែលមានសក្តានុពលបំផុត ដែរនឹងត្រូវពង្រីកចាប់តាំងពី ឆ្នាំ២០១៧ ទៅកាន់កន្លែងដែរមានការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុមិនសូវមាន ហើយប៉ុន្តែតម្រូវការមានកំរិតខ្ពស់។

## គ- ទំហំ និង និន្នាការទីផ្សារ

ការកើនឡើងនូវតម្រូវការទីផ្សាររបស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី រក្សានូវការកើនឡើង ដែរបានបង្ហាញអោយ ឃើញច្បាស់ ដោយកំណើនជាប្រចាំថ្ងៃ នៅក្នុង ទំហំឥណទានប្រកបដោយគុណភាព ចាប់តាំងពីការបង្កើត រហូតដល់ពេលបច្ចុប្បន្ន។ ការរីកចំរើន នៅក្នុងសេដ្ឋកិច្ចទីផ្សារ និង សេដ្ឋកិច្ចកំពុងអភិវឌ្ឍន ត្រូវបានរៀបចំជាគំរោងដើម្បី ធ្វើអោយមានកំណើនឡើងនូវទីផ្សារឥណទាន ដែរបានគាំទ្រដោយតម្រូវការក្នុងស្រុកកាន់តែ ខ្លាំងឡើង ព្រមទាំងការស្តារឡើងវិញនូវតម្រូវការខាងក្រៅ ដែលបានជំរុញ ដោយកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។

ដោយមានឱកាសវិនិយោគក្នុងស្រុកមានកំរិតខ្ពស់ វិស័យធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុ ដ៏ទៃទៀត ដូចជា មីក្រូហិរញ្ញវត្ថុ ដែលបានទទួលនៅផលចំណេញដ៏សន្និកសន្ធាប់ បានទាក់ទាញនូវការវិនិយោគថ្មី ដែរនាំអោយមានការរីកលូតលាស់ក្នុងវិស័យនេះយ៉ាង ឆាប់រហ័ស។ ទាំងនេះបានឆ្លុះបញ្ចាំង ពីការកើនឡើងឥតឈប់ឈរ ក្នុងទ្រព្យសកម្ម ឥណទាន ការដាក់ប្រាក់បញ្ញើ តម្រូវការសម្រាប់ឥណទានធនាគារ និង សេវាកម្មធនាគារដ៏ទៃទៀត។ ភាពជោគជ័យនៅក្នុងវិស័យធនាគារនេះត្រូវបានសន្មត់ដោយគ្មានការសង្ស័យទៅនឹងការ រីកចម្រើនគួរអោយកត់សម្គាល់នៅក្នុង ប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារក្នុងព្រះរាជាណាចក្រមួយនេះ ដែលបានបន្តដើម្បីអភិវឌ្ឍន៍ និងធ្វើអោយប្រសើរឡើងជាលំដាប់។ ការជួយជ្រោមជ្រែងទាំងនេះ បានកសាងនូវទំនុកចិត្ត និង ជំនឿទុកចិត្តថែមទៀតពី សាធារណជន និងអ្នកវិនិយោគនៅក្នុងវិស័យធនាគារ និងវិស័យពាក់ព័ន្ធផ្សេងទៀត ជាលទ្ធផល តម្រូវការមានកំរិតខ្ពស់ សម្រាប់សេវាកម្មហិរញ្ញវត្ថុ និង ធនាគារ ព្រមទាំងសេវាកម្មពាក់ព័ន្ធផ្សេងទៀត។ ការផ្តល់នូវវត្តមាននាពេលបច្ចុប្បន្ននៅក្នុងរីកចំរើន នៃតម្រូវការទីផ្សារចំពោះសេវាកម្មធនាគារទាំងនោះរួមមាន ឥណទាន ប្រាក់បញ្ញើ និងសេវាកម្មផ្សេងៗទៀត នឹងកើនឡើងចំពោះសេវាកម្មទីផ្សារធនាគារ នៅតែល្អដ៏ដែរ។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី មានផែនការណ៍បង្កើតនូវទំនាក់ទំនងល្អជាមួយនឹងក្រុមហ៊ុនជាច្រើនទៀត ដែលរាប់ចាប់តាំងពីមុខរបរនៅតាមផ្ទះ រហូតដល់អាជីវកម្មខ្នាត់មធ្យម ដើម្បីផ្តល់អោយពួកគេនូវសេវាកម្មរបស់ធនាគារ។ តាមរយៈផែនការណ៍អាជីវកម្មធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ជឿជាក់ថា អាជីវកម្មទាំងនោះ អាចនឹងមក ទទួលយកនូវសេវាកម្មធនាគារ ក្នុងគោលបំណងដើម្បីពង្រីក នូវអាជីវកម្ម របស់ពួកគេ។នេះមានន័យថា ទំហំទីផ្សារ និង និន្នាការប្រើប្រាស់សេវា ធនាគារ នឹងត្រូវបាន ពង្រីកកាន់តែធំឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

## ឃ- ការវិភាគពីការប្រកួតប្រជែង

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី មានបុគ្គលិកក្នុងស្រុកដែលមានវិជ្ជាជីវៈជំនាញជាច្រើនផ្នែកនៅក្នុងវិស័យ ធនាគារ គណនេយ្យ ការគ្រប់គ្រងឥណទាន ប្រតិបត្តិការណ៍ ទីផ្សារ និង ការគ្រប់គ្រងធនធានមនុស្ស បូករួមទាំង ថ្នាក់ដឹកនាំកំពូលដែល មានសាវតារមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក ដូចជា ទីក្រុងហុងកុង ប្រទេសចិន កម្ពុជា...។ល។ នេះបានផ្តល់អំណាចអោយយើង នូវសេវាដែលមានគុណភាពដើម្បីបំពេញតំរូវការក្នុងស្រុក អោយបានច្រើនបំផុតសំរាប់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាជាមួយនឹងចំណេះដឹងដ៏ទូលំទូលាយនៅក្នុងការអភិវឌ្ឍន៍អនាគតរបស់ធនាគារ។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី មានបំណងដើម្បីអភិវឌ្ឍន៍ជាធនាគារពាណិជ្ជដែរមានសេវា ពេញលេញ ជាមួយវិស័យអាជីវកម្មមួយចំនួនដូចជា៖

- កសិកម្ម និងអាជីវកម្មខ្នាតតូច
- អាជីវកម្មជាក្រុមហ៊ុន
- អាជីវកម្មជាបុគ្គល
- រតនាគារ

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី នឹងធ្វើការយ៉ាងជិតស្និតជាមួយធនាគារជាតិនៃកម្ពុជា និង ព្រមទាំងធនាគារឯកទេសដែរបានបង្កើតនៅក្នុងស្រុក និង សាខាធនាគារបរទេស ដើម្បីរក្សានូវតួនាទីដ៏សំខាន់នៅក្នុងវិស័យធនាគារក្នុងប្រទេសកម្ពុជា។ យើងនឹងធ្វើការយ៉ាងជិតស្និតផងដែរ ដើម្បីគាំទ្រដល់ អង្គការ ឬ ក្រុមហ៊ុនស្របច្បាប់ដែលមានស្រាប់ ដែលសកម្មភាពឥណទានជនបទ។

ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង នៃធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី គឺជាអ្នកដែលមានវិជ្ជាជីវៈ និងឆន្ទះមុះមុត។ គណៈគ្រប់គ្រង គឺមានចំណេះដឹងវិជ្ជាជីវៈជ្រៀលជ្រះទៅលើ ធនាគារឯកទេស ធនាគារឯកទេសជនបទ ឥណទានសហគមន៍ ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ និង បានបញ្ជាក់នូវការយល់ដឹងនៃលក្ខណៈសម្បត្តិតែមួយគត់ នៃគំរូអាជីវកម្មសេវាហិរញ្ញវត្ថុនីមួយៗ ព្រមទាំង តំរូវការ និងការចង់បាន នៃក្រុមអតិថិជន។

ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ធ្វើប្រតិបត្តិការណ៍របស់ខ្លួនជាមួយការអនុម័តឥណទានដ៏រឹងមាំមួយ ប្រព័ន្ធតាមដាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ដើម្បីធានានូវភាពរឹងមាំ និងស្ថេរភាពហិរញ្ញវត្ថុនៃប្រតិបត្តិការណ៍ធនាគារ។ ធនាគារធ្វើការអនុម័តប្រព័ន្ធតាមដានឥណទានជាប្រាំផ្នែក ជាមួយនឹងតំលៃអត្រាការប្រាក់ដោយផ្អែកលើហានិភ័យ ដើម្បីធានានូវការគ្រប់គ្រងហានិភ័យដ៏ត្រឹមត្រូវមួយ។

# ការពង្រីកអាជីវកម្ម








នៅក្នុងបរិយាកាសអាជីវកម្មដែរ មានភាពអនុគ្រោះល្អប្រសើរដូចជា កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ស្ថេរភាពបរិយាកាសនយោបាយនិងសក្ដានុពលដ៏អស្ចារ្យព្រមទាំងមានជាច្រើនទៀតយើងនឹងគ្រោងដើម្បីកម្លាយខ្លួនពី ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ទៅជា ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក. នៅក្នុងអនាគត ព្រមទាំងនឹងបង្កើតសាខាជាច្រើនក្នុងប៉ុន្មានឆ្នាំខាងមុខទៀតនៅក្នុងរាជធានីភ្នំពេញក្នុងគោលបំណង ដើម្បីពង្រឹងនូវអាជីវកម្ម របស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី និង ទទួលយកផលប្រយោជន៍ ពីការរីកចម្រើននៃសេដ្ឋកិច្ច របស់ ប្រទេសកម្ពុជា និង ការកើនឡើងនៃតម្រូវការសេវាកម្មធនាគារ។

# បណ្តាញសាខា






មានសក្តានុពលអាជីវកម្មដ៏ធំសម្បើម ដើម្បីបង្កើតសាខានៅ ក្នុងរាជធានីភ្នំពេញដែលត្រូវ បានជឿជាក់ដើម្បីពង្រីកនូវចំណែកទីផ្សារទទួលនិង នូវសក្តានុពលជំនួញលើវិស័យ ធនាគារពីផែនការណ៍ពង្រីកសាជីវកម្មថ្មីរបស់យើង។ ទីកន្លែងទាំងនោះស្ថិតនៅទួលទំពុង/អូរឡាំពិក តាម បណ្តោយ មហាវិថីនរោត្តម សង្កាត់ស្ទឹងមានជ័យ និង ផ្សេងៗទៀត ដែលជាទីកន្លែងដែរតម្រូវការមានកំរិតខ្ពស់។ ដើម្បីសម្រេចនូវគោលដៅរបស់យើង យើងត្រូវការកសាងកេរ្តិ៍ឈ្មោះរបស់ធនាគារ ឈីហ្វ ហើយនឹងដើម្បីបង្កើតនូវបណ្តាញអាជីវកម្មមួយ ក្នុងគោលបំណងចង្អុលបង្ហាញនូវវឌ្ឍនភាពរបស់ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី និងភាពខុសប្លែករបស់ធនាគារ ឈីហ្វ ពីគូរប្រកួតប្រជែង។


## អាសយដ្ឋាន ការិយាល័យកណ្តាល

ផ្ទះលេខ សេ ០១ ផ្លូវអ៊ែ ១១ កែងនឹងផ្លូវ៧០ ភូមិ១
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ : 855-23-900 878
ទូរសារ : 855-23-900 858
អ៊ីម៉ែល : info@chiefholdings.com.kh
គេហទំព័រ : www.chiefbank.com.kh

## អាសយដ្ឋាន សាខាច្បារអំពៅ

វិមានកែវចរណៃ ដីឡូត៍លេខ១០៥បេ ផ្លូវជាតិលេខ០១ ភូមិតាង៉ូវ
សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ទូរស័ព្ទ : 855-23-230 488
ទូរសារ : 855-23-230 477